**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៥៤ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារជូនក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងបរិស្ថាន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៤១១ សហវ.ប្រក ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្ដីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១._**

ត្រូវបានធ្វើប្រតិភូកម្មមុខងារជូនប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងបរិស្ថាន ក្នុងការពិនិត្យនិងសម្រេចផ្ដល់ទិដ្ឋាការធានាចំណាយនិងអាណត្តិបើកប្រាក់ សម្រាប់ចំណាយចរន្ត លើគ្រប់មុខសញ្ញាចំណាយ និងដោយមិនកំណត់ទឹកប្រាក់ វៀរលែងតែបដិប្បញ្ញត្តិដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ។

**ប្រការ២._**

ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវស្នើសុំការសម្រេចផ្ដល់ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់ ពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រមដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ចំពោះប្រភេទចំណាយ មុខសញ្ញាចំណាយ និងកម្រិតទឹកប្រាក់ ដូចខាងក្រោម ៖

ក. ចំណាយតាមនីតិវិធីបុរេប្រទានលើគ្រប់មុខសញ្ញាចំណាយដោយមិនកំណត់ទឹកប្រាក់។

ខ. ចំណាយ ទៅតាមអនុគណនី ដូចខាងក្រោម ៖

- ជំពូក៦១ (សេវាកម្ម) ៖ អនុគណនី ៦១០៧១ (សោហ៊ុយសិក្សាពិសោធន៍)
- ជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ៖ អនុគណនី ៦២០២៨ (ជំនួយសង្គមផ្សេងៗទៀត)
- ជំពូក ៦៥ (ឧបត្ថម្ភធន) ៖
    - គ្រប់អនុគណនីនៃគណនី ៦៥០២ (ឧបត្ថម្ភធនដល់អង្គការសាធារណៈ),
    - គ្រប់អនុគណនីនៃគណនី ៦៥០៤ (ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈ),
    - គ្រប់អនុគណនីនៃគណនី ៦៥០៧ (ការចូលរួមក្នុងការអនុវត្តគម្រោង)។

គ. មុខសញ្ញាចំណាយដែលមានទឹកប្រាក់លើសពី ៣០០ លានរៀល ចំពោះការស្នើសុំរបស់អង្គភាពថវិកាតែមួយ ឬដែលមានទឹកប្រាក់លើសពី ៥០០ លានរៀល ចំពោះការស្នើសុំចំណាយដែលប្រមូលផ្តុំអង្គភាពថវិកាច្រើនលើសពីមួយ នូវជំពូក គណនី និងអនុគណនី ដូចខាងក្រោម ៖

- ជំពូក ៦០ (ការទិញ) ៖
  - អនុគណនី ៦០០១៥ - ប្រេងឥន្ធនៈ និងប្រេងរំអិល
  - អនុគណនី ៦០០២៣- ការបោះពុម្ព
  - អនុគណនី ៦០០៥៥ - សម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា
- ជំពូក ៦១ (សេវាកម្ម) ៖
  - អនុគណនី ៦១០៥១ - ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែននេសាទ
  - អនុគណនី ៦១០៥២ - ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ
  - អនុគណនី ៦១០៥៤ - ការថែទាំបណ្តាញផ្សេងៗ
  - គ្រប់អនុគណនីនៃគណនី ៦១០៩ - បុគ្គលិកខាងក្រៅផ្សេងៗ
  - អនុគណនី ៦១១០៣ -ប្រជុំ សិក្ខាសាលា និងសន្និសីទ (សម្រាប់កិច្ចប្រជុំសន្និសីទកម្រិតជាតិ និងអន្តរជាតិ)
- ជំពូក ៦៤ (បន្ទុកបុគ្គលិក) ៖ អនុគណនី ៦៤០៣៣ - រង្វាន់។

**ប្រការ៣.**_

ការធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យថវិកាជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការពិនិត្យ និងសម្រេចផ្តល់ទិដ្ឋាការ ចំពោះការស្នើសុំចំណាយដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ត្រូវអនុលោមតាមការបែងចែកភារកិច្ចដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.**_

ចំពោះការស្នើសុំចំណាយដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ក្នុងករណីពិនិត្យឃើញថាមានវេទយិតភាព ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវស្នើសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម។

**ប្រការ៥.**_

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវរក្សាសាមគ្គីភាព សីលធម៌វិជ្ជាជីវៈ បុរេសកម្ម និងប្រកាន់ខ្ជាប់នូវគោលការណ៍ប្រសិទ្ធភាពនិងចីរភាពថវិកា និងអនុលោមភាពគតិយុត្ត ក្នុងការត្រួតពិនិត្យការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ប្រការ៦.**_

ការធ្វើប្រតិភូកម្មមុខងារខាងលើ អាចជាកម្មវត្ថុនៃការកែសម្រួលឡើងវិញដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការចាំបាច់។

**ប្រការ៧.**_

ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបំពេញមុខងារតាមការធ្វើប្រតិភូកម្មខាងលើនេះ ។

**ប្រការ៨.–**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលស្របតាមបទប្បញ្ញត្តិជាធរមាន ដោយមិនទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត។ អនុលោមតាមបទប្បញ្ញត្តិជាធរមាន ទណ្ឌកម្មរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល រួមមានជាអាទិ៍ ៖

- ការស្ដីបន្ទោស
- ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្ដេញចេញពីមុខតំណែងជាមន្ត្រីរាជការ ។

**ប្រការ៩.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ១០.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងបរិស្ថាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងបរិស្ថាន
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ